ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១១

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំពេញអង្គលើកទី ១០ ត្រូវបានបញ្ចប់

កិច្ចប្រជុំពេញអង្គលើកទី ១០ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបញ្ចប់នៅថ្ងៃនេះ បន្ទាប់ពីបានជួបប្រជុំគ្នាអស់រយៈពេលបីថ្ងៃ ចាប់តាំងពីថ្ងៃច័ន្ទ ទី១ ដល់ថ្ងៃពុធ ទី៣ ខែសីហា ឆ្នាំ២០១១។ កិច្ចប្រជុំពេញអង្គបានពិនិត្យពិភាក្សាលើសំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុងរបស់ខ្លួន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំការជំនុំជម្រះក្តី និងកិច្ចដំណើរការនីតិវិធីជំនុំជម្រះឲ្យបានឆាប់រហ័ស។

ជាលទ្ធផល កិច្ចប្រជុំពេញអង្គ បានអនុម័តសំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុងជាច្រើន។ វិធានផ្ទៃក្នុងពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខភ្លាមៗនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ត្រូវបានធ្វើវិសោធនកម្ម ដើម្បីដាក់បញ្ចូលបទប្បញ្ញត្តិចាំបាច់នានា ដែលតម្រូវឲ្យអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេច ដោយមានសំអាងហេតុសង្ខេបលើបណ្តឹងសាទុក្ខភ្លាមៗក្នុងរយៈពេលបីខែ។ ទាក់ទិននឹងបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះតុលាការកំពូល ក្នុងកាលៈទេសៈពិសេស អាចពន្យាររយៈពេលចេញសេចក្តីសម្រេចនេះបន្ថែមបានមួយខែទៀត។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូល មិនអាចចេញសេចក្តីសម្រេចក្នុងរយៈពេលកំណត់ខាងលើ ឬប្រសិនមិនអាចរកសម្លេងភាគច្រើនលើសលុបក្នុងការសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗបានទេ នោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នឹងមានអានុភាពស្ថាពរ។

វិធានពាក់ព័ន្ធនឹងការស៊ើបអង្កេតលើករណីមរណភាពនៃជនជាប់ចោទដែលស្ថិតក្នុងមន្ទីរឃុំឃាំង ត្រូវបានធ្វើវិសោធនកម្ម ដើម្បីធ្វើឲ្យការវះកាត់ពិនិត្យសាកសពលែងជាកាតព្វកិច្ចចាប់បង្ខំដាច់ខាតទៀតហើយ ស្របតាមការអនុវត្តប្រហាក់ប្រហែលនៅកម្ពុជា និងវិធានជាធរមាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិ។

ចំណែកឯវិសោធនកម្មវិធានផ្ទៃក្នុងបន្ថែមទៀតទាក់ទិននឹងគណៈកម្មាធិការរដ្ឋបាលតុលាការវិញ ដែលនៅពេលនេះ គណៈកម្មាធិការនេះ អាចជួបប្រជុំគ្នាទៅតាមគំនិតផ្តួចផ្តើមរបស់ប្រធាន ជាជាងការជួបប្រជុំគ្នាទៀងទាត់ជារៀងរាល់ខែ។

វិសោធនកម្មមួយចំនួនទៀតក៏ត្រូវបានធ្វើឡើងចំពោះសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ និងការកែសម្រួលពាក្យពេចន៍ចំពោះបទប្បញ្ញត្តិទាក់ទិននឹងបណ្តឹងសាទុក្ខដើម្បីធ្វើឲ្យមានសុខដុមនីយកម្ម នៃភាសាផ្លូវការទាំងបីនៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥(0)១២ ៤៨៨ 0២៣
ទូរស័ព្ទ: +៨៥៥ (0)២៣ ២១៩ ៨៤១ លេខបន្ត: ៦១៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៣ ២៨៣
សារអេឡិកត្រូនិក: neth.pheaktra@eccc.gov.kh